**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមហ៊ុន ហឺរ៉ាយហ្សិន អៅដរ( ខេមបូឌា) ខូ,.អិលធីឌី**

អាសយដ្ឋានៈ ផ្លូវជាតិលេខ ៥ ភូមិផ្សារត្រាច ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

ទូរស័ព្ទលេខៈ០៧៧ ៧៧៧ ៥៦៤ / ០៧០ ៧៧៧ ៥៦៤

## កិច្ចព្រមព្រៀងរវាង

**ភាគី(ក)** ក្រុមហ៊ុន ហឺរ៉ាយហ្សិន អៅដរ (ខេមបូឌា)ខូ,.អិលធីឌី ដែលមានអាសយដ្ឋានៈ ផ្លូវជាតិលេខ ៥ ភូមិផ្សារត្រាច ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំងតំណាងដោយលោកស្រី **ធី គុន្ធា** ។

**និងភាគី(ខ)** តំណាងកម្មករ និងតំណាងសហជីពសិទ្ធិប្រយោជន៍កម្មករប្រចាំក្រុមហ៊ុន ហឺរ៉ាយហ្សិន អៅដរ (ខេមបូឌា)ខូ,.អិលធីឌី ជាតំណាងកម្មករឲ្យកម្មករ-កម្មការនី។

## ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចតទៅ

ប្រការ១៖ ក្រុមហ៊ុនស្នើរសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៣២៥នាក់ (ស្រី ២៨៧នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៧២៨៨នាក់ (ស្រី ៦៨១៣នាក់)រយៈពេល ១ខែ ចាប់ពីថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ២០២០ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០។

ប្រការ២៖ ក្រុមហ៊ុននឹងផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករនិយោជិត ដោយអនុវត្តទៅតាមសេចក្តីជូនដំណឹងស្តីពីការផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករនិយោជិតក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារដែលចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

ប្រការ៣៖ ក្នុងករណីមានការកែប្រែ ភាគីក្រុមហ៊ុន និងបិទផ្សាយព័ត៌មាននៅក្តារប្រកាសព័ត៌មាន និងនៅខាងមុខច្រកចូលក្រុមហ៊ុន ។

ប្រការ៤៖ កិច្ចព្រមព្រៀងនេះនឹងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខារហូតដល់មានការកែសាជាថ្មី។

ថ្ងៃចន្ទ ១កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

កំពង់ឆ្នាំង ថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ២០២០

| ភាគី(ក) | ភាគី(ខ) |
|---|---|
| **នាយក ឬ តំណាងក្រុមហ៊ុន** | **តំណាងកម្មករ និងតំណាងសហជីព** |
| | ១. លោក រឹម សុវណ្ណារិទ្ធ |
| | ២. អ្នកស្រី សុទ្ធ សារីន |
| **លោកស្រី ធី គុន្ធា** | ៣. លោក មាន ចិន្តា |